**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពេញអង្គ
## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១
## ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ តាមបណ្តាញវីដេអូ កម្មវិធី ZOOM

- *សូមគោរពអង្គពិធីទាំងមូល*
- *ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍*
- *ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សក្រៃលែងដោយបានធ្វើជាអធិបតីដើម្បីដឹកនាំ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១"** តាមបណ្តាញវីដេអូ កម្មវិធី **Zoom** ដោយសារតែការគំរាមកំហែងពីជំងឺកូវីដ-១៩ ដែលនៅតែបន្តអូសបន្លាយ ហើយបាននឹងកំពុងបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ស្ថានភាពសុខភាព នយោបាយ សេដ្ឋកិច្ចសង្គម នៅទូទាំងតំបន់ និងពិភពលោកទាំងមូល។ ដោយឡែកនៅប្រទេសកម្ពុជាមកទល់ពេលនេះ ស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ បានបន្តឆ្លងចូលក្នុងសហគមន៍ នៅតាមបណ្តារាជធានី ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជាយើង ដែលខ្ញុំសូមយកឱកាសនេះ អំពាវនាវឱ្យមានការប្រុងប្រយ័ត្នទ្វេដង និងចូលរួមទប់ស្កាត់ការចម្លងទាំងអស់គ្នា ដោយអនុវត្តតាមសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាល និងបន្តអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការ និងកម្មវិធីបង្ការផ្សេងៗរបស់ក្រសួងសុខាភិបាល។

នៅប្រទេសម្ពុជា ការរាតត្បាតជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងលើការវិនិយោគផ្នែកសុខភាពសាធារណៈ ការពង្រឹងប្រព័ន្ធសុខាភិបាល និងសង្គម-សេដ្ឋកិច្ច ព្រមទាំងបានកាត់បន្ថយលទ្ធភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើនដែលមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ បត់បែនទៅតាមសភាពការណ៍ និងភូមិសាស្ត្រ រួមជាមួយការចាក់វ៉ាក់សាំង

បង្កើតភាពស៊ាំក្នុងសហគមន៍ដែលជួយដល់ការគ្រប់គ្រងការឆ្លងមេរោគកូវីដ-១៩ ឆ្ពោះទៅកាត់បន្ថយចំនួនអ្នកចូលសម្រាកក្នុងមន្ទីរពេទ្យ និងកាត់បន្ថយអត្រាមរណភាពដោយមេរោគកូវីដ-១៩ ដែលនេះក៏ជាចូលរួមចំណែកដ៏សំខាន់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ដែរ។

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុត និងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានយកពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពេញអង្គតាមបណ្តាញវីដេអូ នាពេលនេះ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត និងដៃគូ អង្គការជាតិ និងអន្តរជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែង និងសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការចូលរួមក៏ដូចជាការជំរុញអនុវត្ត "សេចក្តីជូនដំណឹងលេខ២១៣ សជណ .សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ក្នុងនោះមានវិធានការ៦ចំណុច ឆ្ពោះទៅកាន់ចីរភាពក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជរដ្ឋាភិបាល និងជាពិសេស ដើម្បីរៀបចំនូវវិធីសាស្ត្រ និងយន្តការនានាក្នុងការឆ្លើយតប នៅក្នុងបរិបទនៃការរាតត្បាតជំងឺកូវីដ-១៩។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!**

ខ្ញុំសូមជម្រាបជូនអង្គពិធីទាំងមូលជ្រាបថា កាលពីដើមខែមិថុនាកន្លងទៅថ្មីៗនេះ ខ្ញុំបានចូលរួម និងដឹកនាំកិច្ចប្រជុំសំខាន់ពីរ ៖

ទី១ នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២១ បានផ្តល់បទអន្តរាគមន៍តាមបណ្តាញវីដេអូក្នុងការដាក់ចេញនូវរបាយការណ៍ថ្មីស្តីពីការប្តេជ្ញាចិត្តជាសកលរបស់អង្គការUNAIDS ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក។ អង្គប្រជុំនេះមានការចូលរួមពីនាយកអង្គការUNAIDS ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ប្រតិភូអង្គការក្រៅរដ្ឋាភិបាល និងថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងមុនកិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ក្នុងនោះ អង្គការ UNAIDS បានបោះពុម្ពផ្សាយរបាយការណ៍ថ្មី ដែលមានចំណងជើងថា "ការប្តេជ្ញាចិត្តសកលសកម្មភាពនៅមូលដ្ឋាន ៖ ការកសាងរយៈពេលពីរទសវត្សនៃសាមគ្គីភាពសកលដើម្បីបញ្ចប់អេដស៍"។

ទី២ គឺពីថ្ងៃទី៨-១០ ខែមិថុនា ដោយបានទទួលការចាត់តាំងដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំបានដឹកនាំប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់របស់អង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ នៅទីស្នាក់ការកណ្តាលរបស់អង្គការសហប្រជាជាតិនាទីក្រុងញូវយ៉ក តាមរយៈប្រព័ន្ធវីដេអូ ដែលផ្តោតសំខាន់ទៅលើ ការដោះស្រាយវិសមភាពក្នុងការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០៣០ ការលើកកម្ពស់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនិងក្មេងស្រីក្នុងការឆ្លើយតបនឹងជំងឺអេដស៍ ព្រមទាំងដោះស្រាយផលប៉ះពាល់នៃជំងឺរាតត្បាតនានាទាក់ទងនឹងការឆ្លើយតបនឹងជំងឺអេដស៍។ នៅក្នុងឱកាសនោះ ខ្ញុំបានថ្លែងនូវសេចក្តីថ្លែងការណ៍របស់ព្រះរាជាណាចក្រ

កម្ពុជា តាមរយៈការថតវីដេអូចាក់ផ្សាយផ្ទាល់ក្នុងសម័យប្រជុំអង្គការសហប្រជាជាតិ ដោយមានឯកឧត្តម តំណាងបេសកកម្មអចិន្ត្រៃយ៍ប្រទេសកម្ពុជា ប្រចាំនៅញូវយ៉ក បានអញ្ជើញចូលរួមផ្ទាល់ផងដែរ។

សេចក្តីថ្លែងការណ៍នេះ បានបញ្ជាក់ពីសមិទ្ធផលនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ជាមួយនឹងគោលជំហរក្នុងការឆ្ពោះទៅសម្រេចឱ្យបាននូវ សេចក្តីប្រកាសនយោបាយស្តីពីមេរោគអេដស៍ និងជំងឺអេដស៍របស់ អង្គការសហប្រជាជាតិ ក្រោមពាក្យស្លោក "**ការបញ្ចប់វិសមភាព និងការឈានទៅរកការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០៣០**" ដែលសមិទ្ធផលទាំងនេះ បានសម្រេចឡើងដោយមានការចូលរួមពីក្រសួង ស្ថាប័ន ភាគីពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការជាតិ និងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សហគមន៍អ្នកផ្ទុកមេរោគអេដស៍ ប្រជាជនគន្លឹះ និងប្រជាជនងាយរងគ្រោះទូទាំងប្រទេស។ ខ្លឹមសារលម្អិត ឯកឧត្តម ទា ផលា នឹងធ្វើបទបង្ហាញក្នុងរបៀបវារៈនៃកិច្ចប្រជុំ របស់យើងនៅព្រឹកនេះ។

តាមរបៀបវារៈនៃកិច្ចប្រជុំ យើងនឹងមានបទបង្ហាញចំនួន៣ ដែលក្នុងនោះរួមមាន ៖

ទី១ បទបង្ហាញស្តីពីរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០២១ បង្ហាញជូនដោយឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អ.ជ.ប.ជ.អ.។ បទបង្ហាញនេះធ្វើឡើងដើម្បីឱ្យមានការយល់ដឹងច្បាស់ពីលទ្ធផលដែលយើងទទួលបានក្នុងការអនុវត្តផែនការសកម្មភាព ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២១ និងទិសដៅបន្តសម្រាប់៦ខែបន្ទាប់។

ទី២ បទបង្ហាញស្តីពី "លទ្ធផលនៃកិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍នៅញូវយ៉ក ថ្ងៃទី៨-១០ ខែមិថុនា ឆ្នាំ២០២១" ដោយឯកឧត្តមវេជ្ជបណ្ឌិត **ទា ផលា** អនុប្រធាន អ.ជ.ប.ជ.អ.។

ទី៣ បទបង្ហាញស្តីពី "សេចក្តីប្រកាសនយោបាយនៃកិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ របស់អង្គការសហប្រជាជាតិ ឆ្នាំ២០២១ និងដំណើរឆ្ពោះទៅអនាគត" ដោយ **Dr. Khin Cho Win Htin** ទីប្រឹក្សាព័ត៌មានយុទ្ធសាស្ត្រ និងលោក **អ៊ឹង ប៉ូលីន** ទីប្រឹក្សាបច្ចេកទេសរបស់អង្គការUNAIDS ប្រចាំប្រទេសកម្ពុជា។

ចំណុចសំខាន់នៃអង្គប្រជុំយើងថ្ងៃនេះ គឺការអនុម័តនូវសេចក្តីសម្រេចចិត្តរបស់យើងដែលបានដាក់ជូនសមាជិក សមាជិកា តាមប្រព័ន្ធអេឡិចត្រូនិករួចហើយ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមបញ្ជាក់ថា យើងបាននិងកំពុងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ស.ជ.ណ ២១៣ ដើម្បីសម្រេចនូវគោលដៅ ៩៥-៩៥-៩៥ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖ ១) ធ្វើបច្ចុប្បន្នភាពនៃគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ២) សម្របសម្រួលកិច្ចប្រជុំរបស់គណៈកម្មាធិការឱ្យបានទៀងទាត់ ៣) រៀបចំផែនការសកម្មភាព ៤) បែងចែកនូវប្រភពធនធាន និង៥) អនុវត្ត និងតាមដានផែនការសកម្មភាព។

ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លទ្ធផលដែលទទួលបានពីកិច្ចប្រជុំនេះ ពិតជាមានសារៈសំខាន់ ដែលនឹងផ្តល់ទៅដល់ក្រុមការងារបច្ចេកទេស អាចយកទៅប្រើប្រាស់ក្នុងការបន្តការអនុវត្តការងារឆ្លើយតបទៅ

នឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ នាពេលខាងមុខ ទៅតាមអនុសាសន៍ដែលនឹងផ្តល់ជូនក្នុងសម័យប្រជុំពេញអង្គនាពេលនេះ។

ដើម្បីទុកពេលវេលាឱ្យបានច្រើនដល់ការធ្វើបទបង្ហាញ និងការពិភាក្សាផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ការងារពីបណ្តាសមាជិកសមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ខ្ញុំសូមបញ្ចប់សុន្ទរកថាបើកកិច្ចប្រជុំនាពេលនេះតែប៉ុណ្ណេះ។

ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ឱ្យមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាវាងវៃ ដើម្បីចូលរួមពិភាក្សាឱ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក និងសូមប្រកាសបើក "**កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២១**" ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**